# គ្មានអ្វីងាយស្រួលនោះឡើយ ?

ថ្ងៃទី៩ វិច្ឆិកា កាន់តែរំកិលមកដល់ថ្ងៃសន្យា, ចំពោះលោក សម រង្ស៊ី គាត់នៅតែរក្សាពាក្យសច្ចាថា ធ្វើមាតុភូមិនិវត្ត ដើម្បី ស្តារលទ្ធិប្រជាធិបតេយ្យ។ គាត់ធ្វើមរតកសាសន៍ បញ្ជាក់អំពីពលកម្មចាំបាច់ រហូតប្តូរជីវិត ដែលគាត់ត្រូវតែធ្វើ នៅចំពោះមុខការលើកទ័ពរបស់ ហ៊ុន សែន ចេញច្បាំងនឹងគាត់ និង ខ្មែរដែលហ៊ានចេញមុខប្រឆាំងតាមសន្តិវិធីនឹងរបបផ្តាច់ការ។ តែអ្នកខ្លះ យល់ឃើញថា អំពើហិង្សានេះ ជាការការពារខ្លួនពេញសិទ្ធិ, ចុះអ្នកបះបោរវិញ តើ គេមិនអាចមានសិទ្ធិសោះនោះឡើយ ? យើងយល់ឃើញថា ថ្ងៃទី ៩ វិច្ឆិកា វាគ្មានអ្វីងាយស្រួលសំរាប់ ក្រុម ហ៊ុន សែន និង ខ្មែរបះបោរ នោះទេ។ តែខ្មែរទាំងសងខាង អាចមានដំណោះស្រាយ ដោយយកការបោះឆ្នោតដោយសេរី និង យុត្តិធម៌ ព្រោះជាការងាយស្រួលបំផុត។ នៅក្នុងបរិបទខ្មែរសព្វថ្ងៃ ត្រូវ ហ៊ុន សែន មានសតិសម្បជញ្ញៈថា បើមាន ជនខ្មែរអហិង្សាតែមួយនាក់ស្លាប់ ដោយអាវុធរបស់ពួកគាត់នៅថ្ងៃទី ៩ វិច្ឆិកា គាត់ច្បាស់ជា ត្រូវមតិសហគមអន្តជាតិផ្តន្ទាទោសគាត់ ហើយកម្មវិបាកនឹងមានដល់ខ្លួនគាត់ជាពុំខាន។ ត្រូវដឹងថា ទោះបី ហ៊ុន សែន មានរូបភាពសិប្បនិម្មិតជា នាយករដ្ឋមន្ត្រីស្របច្បាប់លើឆាកអន្តរជាតិ តែគេទុកគាត់ជាជនផ្តាច់ការ ប្រើអំពើទុច្ចរិតគ្រប់បែបយ៉ាង ដើម្បីរក្សាអំណាចផ្ទាល់ខ្លួន និង ក្រុមគ្រួសាររបស់គាត់៕

ឧប សៅ សន្ធា គំនិត ២ វិច្ឆិកា ២០១៩